# សង្កាត់សាលារៀនអូនឡិនដ៍

## កម្មវិធីផ្តល់សេវា និងកម្មវិធីបង្រៀនយ៉ាងល្អិតល្អន់ដើម្បីតេសធំ CAHSEE

## សេចក្តីជូនដំណឹងអំពីភាពមានលក្ខខ័ណ្ឌគ្រប់គ្រាន់នៃសិស្ស

| |
|---|
| កំណត់សំគាល់ : ក្រមអប់រំលេខ 37254 តម្រូវឲ្យសេចក្តីជូនដំណឹងដូចតទៅនេះ ដាក់បិទប្រកាសជូននៅតាមការិយាល័យសាលារៀននៃសាលានិមួយៗ ណាដែលបំរើកូនសិស្សថ្នាក់ទី 10-12, បិទប្រកាស់នៅតាមការិយាល័យសង្កាត់ និងនៅតាមវិបសៃអ៊ិនធឺណិតនៃសង្កាត់សាលារៀន។ សេចក្តីជូនដំណឹងនេះ ត្រូវប្រតិបត្តិតាមតម្រូវការបកប្រែនានាដូចបានចែងនៅក្នុងក្រមអប់រំលេខ 48985។ |

## សេចជូនដំណឹងដល់ មាតាបិតា/អ្នកអាណាព្យាបាល និងកូនសិស្សទាំងឡាយ :
## ភាពមានលក្ខខណ្ឌគ្រប់គ្រាន់នៃកូនសិស្សសំរាប់ជំនួយក្នុងការត្រៀមខ្លួនដើម្បីការប្រឡងតេសធំចេញពីសាលាហៃស្គូលកាលីហ្វូណញ៉ា បន្ទាប់ពីថ្នាក់ទី 12

មាតាបិតា/អ្នកអាណាព្យាបាល និងកូនសិស្សទាំងឡាយ :

ដោយអនុលោមទៅតាមក្រមអប់រំលេខ 37254 នៃកាលីហ្វូនញ៉ា តាមរយៈនេះលោកអ្នកត្រូវបានផ្តល់ជូនជាដំណឹងថា :

1. កូនសិស្ស រួមទាំងអ្នករៀនអង់គ្លេស ណាដែលប្រឡងមិនជាប់មួយផ្នែក ឬទាំងពីរផ្នែកនៃតេសធំប្រឡងចេញពីសាលាហៃស្គូលនៃកាលីហ្វូណញ៉ា (ហៅកាត់ថា CAHSEE) នៅចុងថ្នាក់ទី 12 នោះ មានសិទ្ធទទួលសេវា និងកម្មវិធីបង្រៀនយ៉ាងល្អិតល្អន់ សំរាប់រយៈពេលដល់ទៅពីរឆ្នាំសិក្សាជាប់ៗគ្នា ក្រោយពីបានបញ្ចប់ថ្នាក់ទី 12 ឬរហូតទាល់តែពួកគេប្រឡងជាប់ទាំងពីរផ្នែកនៃតេសធំ CAHSEE។

2. អ្នករៀនអង់គ្លេស ណាដែលប្រឡងមិនជាប់មួយផ្នែក ឬទាំងពីរផ្នែកនៃតេសធំ CAHSEE នៅចុងថ្នាក់ទី 12 នោះ មានសិទ្ធិទទួលសេវានានាដើម្បីបណ្តុះបណ្តាលជំនាញខាងភាសាអង់គ្លេសឲ្យបានកាន់តែល្អប្រសើរឡើង តាមសេចក្តីត្រូវការដើម្បីឲ្យប្រឡងជាប់ផ្នែកនានានៃតេសធំ CAHSEE ដែលពួកគេប្រឡងមិនទាន់ជាប់ ក្នុងរយៈពេលដល់ទៅពីរឆ្នាំសិក្សាជាប់ៗគ្នា ក្រោយពីរៀនចប់ថ្នាក់ទី 12 ឬរហូតទាល់តែពួកគេប្រឡងជាប់ទាំងពីរផ្នែកនៃតេសធំ CAHSEE និង

3. កូនសិស្សទាំងឡាយណាដែលប្រឡងមិនជាប់មួយផ្នែក ឬទាំងពីរផ្នែកនៃតេសធំ CAHSEE នៅចុងថ្នាក់ទី 12 នោះ មានសិទ្ធដាក់ពាក្យទាមទារសុំសេវា និងកម្មវិធីបង្រៀងយ៉ាងល្អិតល្អន់មួយ ក្រោមនីតិវិធីបណ្តឹងដូចគ្នា បើសិនជាពួកគេពុំត្រូវបានផ្តល់ជូននូវឱកាសទទួលបាននូវសេវា និងកម្មវិធីបង្រៀនយ៉ាងល្អិតល្អន់ ដល់ទៅរយៈពេលពីរឆ្នាំសិក្សាជាប់ៗគ្នា ក្រោយពីបានរៀនចប់ថ្នាក់ទី 12 ឬរហូតទាល់តែពួកគេប្រឡងជាប់ទាំងពីរផ្នែកនៃតេសធំ CAHSEE ទេនោះ។

បើសិនជាលោកអ្នកមានសំណួរណាមួយអំពីភាពមានលក្ខខណ្ឌគ្រប់គ្រាន់សំរាប់សេវានានា ឬប្រាថ្នាចង់ទទួលបាននូវសេវានានា សូមទាក់ទងការិយាល័យ CAHSEE នៃសង្កាត់ តាមរយៈទូរស័ព្ទលេខ 879-8859។ បើសិនជាលោកអ្នកចង់ដាក់ពាក្យទាមទារសុំសេវានានា លោកអ្នកអាចអញ្ជើញមកយកបែបបទ និងនីតិវិធីដាក់ពាក្យទាមទារមួយច្បាប់ នៅតាមការិយាល័យសាលារៀនណាមួយ ឬពីការិយាល័យអ្នកទទួលពាក្យបណ្តឹងពីប្រជាជនរបស់សង្កាត់ (1025 2nd Avenue, បន្ទប់លេខ 316, Oakland, CA 94606), ឬអាចទាញយកពីវិបសៃរបស់សង្កាត់ http://webportal.ousd.k12.ca.us - នៅក្រោម (1) Services & Department (សេវានិងក្រសួងនានា) (2) Ombudsperson (អ្នកទទួលពាក្យបណ្តឹងពីប្រជាជន) (3) Williams/Valenzuela UCP Complaint form (បែបបទសំរាប់ដាក់ពាក្យទាមទារតាមនីតិវិធី Williams/Valenzula)។